មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះរាជហស្តលេខា នេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃ ពុធ ទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៤*

ក្នុងព្រះបរមនាម និង តាមព្រះរាជបំណារ

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

# II.ទីស្តីការគណៈរដ្ឋមន្ត្រី

## ១- អនុក្រឹត្យ

*រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៤*

**អនុក្រឹត្យលេខ ៤១ អនក្រ**

**ស្តីពី**

**ការបង្កើតនាយកដ្ឋាន**

**ឃោសនា កងយោធពលខេមរភូមិន្ទ**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ័ន្ត ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ័ន្ត ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល